# ទារកកើតមកប្រដាប់ភេទប្រុសផងស្រីផង

ព័ត៌មានសម្រាប់គ្រួសារ

## សូមសម្តែងនូវការអបអរសាទរចំពោះការកើតមកនៃទារករបស់អ្នក!

អ្នកបានទទួលសន្លឹកព័ត៌មាននេះ ដោយសារតែទារករបស់អ្នកបានកើតមកមានប្រដាប់ភេទដែលខុសប្លែកបន្តិច (ប្រដាប់ភេទប្រុសផងស្រីផង)។ ភាពខុសគ្នានៃប្រដាប់ភេទទាំងនេះ ជួនកាលត្រូវបានគេហៅថា ‘ភាពប្រែប្រួលនៃអន្តរភេទ’, ‘ភាពខុសគ្នានៃការបង្កបង្កើតភេទ' ឬ ‘ភាពប្រែប្រួលនៃចរិតលក្ខណៈភេទ’។

យើងយល់ថានេះអាចជាភាពតានតឹងចំពោះអ្នក ទោះបីជាវាមិនចាំបាច់បង្កឱ្យមានការព្រួយបារម្ភធ្ងន់ធ្ងរក៏ដោយ។ ប្រសិនបើការកំណត់ភេទរបស់កូនអ្នកមិនបានសម្គាល់ដឹងច្បាស់ភ្លាមៗទេនោះ វាអាចសម្គាល់ដឹងបានដោយការគាំទ្រពីអ្នកជំនាញសុខភាព។ ភាពប្រែប្រួលនៃចរិតលក្ខណៈភេទ មានលក្ខណៈជាទូទៅជាងកាលមនុស្សគិតទៅទៀត - គឺមានប្រហែលស្មើនឹងចំនួនមនុស្សដែលមានសក់ក្រហម - ហើយជាផ្នែកនៃភាពចម្រុះរបស់មនុស្សលោកយើង។ មនុស្សដែលមានការប្រែប្រួលទាំងនេះ អាចនាំមកនូវជីវិតដែលសប្បាយរីករាយ និងមានសុខភាពល្អ។

ភាពប្រែប្រួលនៃអន្តរភេទ មិនតែងតែជាប់ទាក់ទងជាមួយបញ្ហាផ្នែកវេជ្ជសាស្ត្រទេ ក៏ប៉ុន្តែមានបញ្ហាសុខភាពច្បាស់ប្រាកដមួយចំនួនដែលទាក់ទងនឹងភាពប្រែប្រួលនៃអន្តរភេទជាក់លាក់។ នេះមានន័យថា ទារករបស់អ្នកអាចត្រូវគេរក្សាទុកក្នុងមន្ទីរពេទ្យរយៈពេលពីរបីថ្ងៃដើម្បីពិនិត្យឡើងវិញ។

វាមានសារៈសំខាន់ណាស់ក្នុងការទទួលបានព័ត៌មានត្រឹមត្រូវដើម្បីយល់ដឹងពីបញ្ហា និងហានិភ័យដែលទាក់ទងនឹងភាពប្រែប្រួលនៃអន្តរភេទដ៏ជាក់លាក់របស់កូនអ្នក ដើម្បីធ្វើការសម្រេចចិត្តដោយត្រឹមត្រូវអំពីការថែទាំ និងការព្យាបាលដ៏ល្អបំផុតរបស់ពួកគេ។

អ្នកនឹងត្រូវបានគេបញ្ជូនទៅមន្ទីរពេទ្យ Royal Children's Hospital (មន្ទីរពេទ្យកុមារ) ឬមន្ទីរពេទ្យ Monash Children’s Hospital (មន្ទីរពេទ្យកុមារម៉ូណាស្ហ) ដែលអ្នកនឹងទទួលបានការគាំទ្រពីក្រុមអ្នកជំនាញវិជ្ជាជីវៈផ្នែកសុខភាព។ លទ្ធភាពទទួលបានក្រុមគាំទ្រអ្នកឯកទេសក៏មានផ្តល់ជូនដែរ។ យើងសូមលើកទឹកចិត្តឱ្យអ្នកនិយាយទៅកាន់អ្នកគាំទ្រដែលមានជំនាញវិជ្ជាជីវៈ និងក្រុមអ្នកគាំទ្រទាំងនេះ ដែលអាចឆ្លើយសំណួររបស់អ្នក និងផ្តល់ព័ត៌មានបន្ថែមជូនអ្នក។

## ប្រកាសអំពីការកើតមកនៃទារករបស់អ្នក

នៅពេលប្រកាសពីការកើតមកនៃទារករបស់អ្នកដល់គ្រួសារ និងមិត្តភក្តិ អ្នកប្រហែលជាចង់ ឬមិនចង់សំដៅទៅលើភេទរបស់ទារក (ប្រុស / ស្រី)។ អ្នកគ្រាន់តែចាប់ទទួលស្គាល់ទារករបស់អ្នក ហើយមិនចាំបាច់បញ្ចេញប្រាប់ពីភេទនៅដំណាក់កាលនេះទេ។

ប្រសិនបើអ្នកចង់និយាយជាមួយគ្រួសារ និងមិត្តភក្តិ អ្នកអាចនិយាយបានថាមានភាពមិនច្បាស់លាស់ខ្លះ ហើយវេជ្ជបណ្ឌិតនឹងទទួលបានព័ត៌មានបន្ថែមទៀតក្នុងរយៈពេលពីរបីថ្ងៃបន្ទាប់។ ប្រសិនបើមានគេសួរ ហើយអ្នកមិនចង់ឆ្លើយតប អ្នកប្រហែលជាចង់និយាយថា អ្នកមានសុខភាពល្អទេ ហើយម្តាយនិងទារកកំពុងសម្រាក។ ជម្រើសមួយណាទាំងពីរនេះគឺត្រឹមត្រូវ ចូរធ្វើអ្វីដែលសក្តិសមបំផុតសម្រាប់អ្នក និងគ្រួសាររបស់អ្នក។

អ្នកអាចប្រាថ្នានៅរង់ចាំរហូតដល់ភេទរបស់ទារកអ្នកត្រូវបានគេកំណត់ មុនពេលជ្រើសរើសឈ្មោះ។ អ្នកមានពេលរហូតដល់៦០ថ្ងៃបន្ទាប់ពីកំណើតទារកដើម្បីចុះឈ្មោះទារករបស់អ្នក។ ក្នុងពេលជាមួយគ្នានេះដែរ អ្នកអាចដាក់ឈ្មោះក្រៅសម្រាប់ទារករបស់អ្នក ហើយវាជារឿងធម្មតាទេដែលគ្រួសារត្រូវចំណាយពេលខ្លះដើម្បីសម្រេចចិត្តដាក់ឈ្មោះទារករបស់ពួកគេ។

## ជំហានបន្ទាប់

ជំហានបន្ទាប់សម្រាប់អ្នក និងទារករបស់អ្នកគឺត្រូវគេបញ្ជូនទៅក្រុមគ្រូពេទ្យឯកទេសជំនាញដែលនឹងធ្វើការពិនិត្យ និងធ្វើតេស្តបន្ថែមទៀត ឧទាហរណ៍:

- ពិនិត្យមើលតំបន់ប្រដាប់ភេទរបស់ទារកអ្នក

- ពិនិត្យមើលសរីរាង្គខាងក្នុង (ជាធម្មតាដោយអ៊ុលត្រាសោន)
- ការធ្វើតេស្តឈាម និងទឹកនោម
- ការធ្វើតេស្តឈាមដើម្បីមើលហ្សែនរបស់ទារក។

ក្រុមនេះនឹងផ្តល់ជូនអ្នកនូវព័ត៌មានបន្ថែម ដើម្បីជួយអ្នកឱ្យយល់ដឹងថាតើលទ្ធផលនៃការធ្វើតេស្តមានន័យដូចម្តេចដែរចំពោះអ្នក។ ពួកគេនឹងជួយគាំទ្រអ្នក និងថែរក្សាកូនរបស់អ្នកនៅគ្រប់វ័យកុមារ ហើយប្រសិនបើចាំបាច់ ពួកគេនឹងជួយអ្នកក្នុងការសម្រេចថាតើត្រូវចិញ្ចឹមទារករបស់អ្នកក្នុងភាពជាក្មេងស្រី ឬក្មេងប្រុស។ ក្រុមអ្នកឯកទេសនឹងជួយអ្នក ដើម្បីជួយកូនរបស់អ្នកឱ្យបានល្អបំផុត និងស្វែងយល់ពីជម្រើសទាំងអស់ដែលមានផ្តល់សម្រាប់កូនរបស់អ្នកពេលណាពួកគេធំឡើង។

វាជាការសំខាន់ណាស់ក្នុងការចំណាយពេលរបស់អ្នក នៅពេលធ្វើការសម្រេចចិត្តជំនួសឱ្យទារករបស់អ្នកអំពីការព្យាបាលរូបគេ។ ការព្យាបាលជាច្រើនអាចពន្យារពេលបាន រហូតដល់ទារករបស់អ្នកមានអាយុគ្រប់គ្រាន់ក្នុងការសម្រេចចិត្តដោយខ្លួនឯង។ ចូរស្វែងរកដំបូន្មាន និងពិចារណាគ្រប់ជម្រើសទាំងអស់ រួមទាំងការមិនព្យាបាល ពេលណាដែលអាចធ្វើទៅបាន។

## មូលហេតុ

រវាងទារក១ ទៅ២ភាគរយកើតមកដោយមានទម្រង់ភាពប្រែប្រួលនៃអន្តរភេទ ឬភាពប្រែប្រួលនៃចរិតលក្ខណៈភេទ។ ចំនួនទាំងនេះរួមមានការប្រែប្រួលបន្តិចបន្តួចនៃការលូតលាស់ប្រដាប់បន្តពូជដែលមិនតម្រូវឱ្យមានការទាក់ទង ឬការណាត់ជួបជាបន្តបន្ទាប់ដ៏យូរអង្វែងជាមួយប្រព័ន្ធសុខភាពឡើយ។ មានតែចំនួនតិចតួចនៃភាពខុសគ្នាទាំងនេះប៉ុណ្ណោះ ដែលបណ្តាលឱ្យមានការលេចឡើងនៃអង្គជាតិដែលមិនអាចកំណត់បានអំពីភេទ។

ភាពខុសគ្នានៃរូបរាងប្រដាប់ភេទ (ប្រដាប់ភេទប្រុសផងស្រីផង) អាចបណ្តាលមកពីកត្តាមួយចំនួនរួមមានអ័រម៉ូន, ក្រូម៉ូសូម (កត្តាហ្សែន) ឬលក្ខណៈរាងកាយផ្សេងទៀត។ ភាពប្រែប្រួលនៃអន្តរភេទ គឺខុសពីអត្តសញ្ញាណភេទ (របៀបដែលមនុស្សកំណត់លើភេទ) និងការនិយមផ្លូវភេទ (ដែលមនុស្សត្រូវបានទាក់ទាញចិត្ត)។

## ការគាំទ្រ

ជាមួយនឹងការគាំទ្រពីក្រុមអ្នកជំនាញវិជ្ជាជីវៈពេទ្យ ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នក អ្នកអាចស្វែងរកការគាំទ្រពីអ្នកដទៃទៀតដែលមានបទពិសោធន៍ស្រដៀងនឹងអ្នកដែរ។

សម្រាប់ព័ត៌មានទំនាក់ទំនងបន្ថែម៖

- អ្នកសម្របសម្រួលគ្លីនិកនៃមន្ទីរពេទ្យកុមារ៖ (03) 9345 7033 ឬ (03) 9345 5522 (ប្រតិបត្តិករទូរស័ព្ទ)
- មន្ទីរព្យាបាលជំងឺផ្លូវទឹកនោម នៃមន្ទីរពេទ្យម៉ូណាស្ទ៖ (03) 9594 4723
- AISSGA (Androgen Insensitivity Syndrome Support Group Australia) <http://www.aissga.org.au>
- Australian X and Y Spectrum Support (AXYS) <https://axys.org.au>
- CAH Support Group Australia <http://www.cah.org.au>
- Genetic Support Network Victoria <https://www.gsnv.org.au>
- Intersex Human Rights Australia <https://ihra.org.au>
- Turner Syndrome Association of Australia <https://www.turnersyndrome.org.au>.

---

ដើម្បីទទួលបានការបោះពុម្ពផ្សាយនេះក្នុងទម្រង់ដែលអាចចូលប្រើបាន អ៊ីម៉េល DHHS diversity <diversity@dhhs.vic.gov.au>

ត្រូវបានអនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋវិចថូរៀ 1 Treasury Place, Melbourne។
© រដ្ឋវិចថូរៀ ក្រសួងសុខភាព និងសេវាកម្មមនុស្ស ខែមីនា ឆ្នាំ២០១៩។
© State of Victoria, Department of Health and Human Services, March 2019.
ISBN 978-1-76069-686-3 (pdf/អនឡាញ/MS word) ISBN 978-1-76069-753-2 (បោះពុម្ព)
អាចរកបាននៅ Health of people with intersex variations <https://www2.health.vic.gov.au/about/populations/lgbti-health/health-of-people-with-intersex-variations>
បោះពុម្ពដោយ TDC3, Richmond (1810017 banner)